00283834

E15

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 02 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ឆ្នាំ ២០០៧/អវតក/អជសដ
Case File/Dossier N° 001/18-07-2007/ECCC/TC

| | |
|---|---|
| **ចំពោះមុខ** | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **ធូ មណី** |
| កាលបរិច្ឆេទ | ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩ |
| ប្រភេទឯកសារ | សាធារណៈ |

# ដីកាសម្រេចកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តី និងថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែដំបូង

**សហព្រះរាជអាជ្ញា**

ជា លាង

Robert PETIT

**ជនជាប់ចោទ**

កាំង ហ្កេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី

ហុង គឹមសួន

យុង ផានិត

**មេធាវីជនជាប់ចោទ**

ការ សាវុត

François ROUX

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

E.C.C.C. TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE

00283835

E15

គីម ម៉េងឃី

ម៉ុច សុវណ្ណារី

Silke STUDZINSKY
Martine JACQUIN
Philippe CANNONE

ទី ស្រីនណា

Pierre Oliver SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE
Elizabeth RABESANDRATANA
Karim KHAN

យើងចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ **កាំង ហ្គេកអ៊ាវ** ហៅ ឌុច ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ ("សេចក្តីសម្រេច") ។

**ដោយពិចារណាលើ** លទ្ធផលនៃសវនាការបឋមដែលបានធ្វើឡើងនៅថ្ងៃទី ១៧ និងទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩។

**បានកត់សម្គាល់ឃើញថា** ថ្ងៃទី ១៤ ដល់ទី ១៦ ខែ មេសា ឆ្នាំ ២០០៩ ថ្ងៃទី ០១ ទី ០៨ និងទី ១២ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០៩ និងថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០០៩ គឺជាថ្ងៃឈប់សម្រាកជាតិ។

**ដោយពិចារណាលើ** សវនាការទាំងឡាយរបស់អង្គបុរេជំនុំជម្រះនឹងត្រូវបានកំណត់ដាក់នៅថ្ងៃព្រហស្បតិ៍ ទី ០២ និងថ្ងៃសុក្រ ទី ០៣ ខែ មេសា ឆ្នាំ ២០០៩ និងពីថ្ងៃច័ន្ទ ទី ០១ ដល់ថ្ងៃសុក្រ ទី ០៥ ខែ មិថុនា ឆ្នាំ ២០០៩។

**ដោយពិចារណាអំពី** ភាពចាំបាច់ក្នុងការជូនដំណឹងឱ្យបានគ្រប់គ្រាន់អំពីកាលបរិច្ឆេទសវនាការដល់ភាគីទាំងអស់។

## ហេតុដូច្នេះ

**សម្រេចថា** សវនាការលើអង្គសេចក្តីចំពោះសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ ទាក់ទងនឹងជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** នឹងចាប់ផ្តើមនៅថ្ងៃច័ន្ទ ទី ៣០ ខែ មីនា ឆ្នាំ ២០០៩ នៅម៉ោង ១០ ព្រឹក នៅសាលសវនាការនៃ អ.វ.ត.ក.។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

00283836

E15

**សម្រេចថា** សវនាការនឹងបន្តនៅថ្ងៃអង្គារ ទី ៣១ ខែ មីនា និងថ្ងៃពុធ ទី ០១ ខែ មេសា ឆ្នាំ ២០០៩ នៅម៉ោង ៩ ព្រឹក និងបន្ទាប់មក ពីថ្ងៃច័ន្ទ ដល់ថ្ងៃព្រហស្បតិ៍ នៅម៉ោង ៩ ព្រឹក រៀងរាល់សប្ដាហ៍ ចាប់ពីថ្ងៃច័ន្ទ ទី ០៦ ខែ មេសា ឆ្នាំ ២០០៩ ដល់ថ្ងៃព្រហស្បតិ៍ ទី ០២ ខែ កក្កដា ឆ្នាំ ២០០៩ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអង្គជំនុំជម្រះសាលាដំបូង និងលើកលែងចំពោះរយៈពេលដែលបានចង្អុលបង្ហាញខាងក្រោមនេះ។

**សម្រេចថា** អង្គជំនុំជម្រះសាលាដំបូងនឹងកំណត់រយៈពេលឈប់សម្រាកធ្វើសវនាការចំនួនពីរលើក គឺចាប់ពីថ្ងៃច័ន្ទ ទី ១៣ ដល់ថ្ងៃសុក្រ ទី ១៧ ខែ មេសា ឆ្នាំ ២០០៩ និងពីថ្ងៃសុក្រ ទី ០១ ដល់ថ្ងៃសុក្រ ទី ១៥ ខែ ឧសភា ឆ្នាំ ២០០៩។ ក្នុងរយៈពេលទាំងពីរនេះ ផ្នែកគ្រប់គ្រងតុលាការ នឹងមិនទទួលការដាក់ឯកសារណាមួយសម្រាប់សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ ឡើយ។ រយៈពេលកំណត់សម្រាប់ការដាក់ឯកសារនឹងត្រូវគិតក្នុងអំឡុងពេលឈប់សម្រាកសវនាការនេះ។ ប៉ុន្តែប្រសិនបើរយៈពេលកំណត់នេះនឹងត្រូវផុតកំណត់ក្នុងថ្ងៃណាមួយនៅក្នុងរយៈពេលឈប់សម្រាកសវនាការនេះ រយៈពេលកំណត់នេះអាចនឹងត្រូវពន្យារទៅថ្ងៃធ្វើការបន្ទាប់ គឺថ្ងៃច័ន្ទ ទី ២០ ខែ មេសា ឆ្នាំ ២០០៩ និងថ្ងៃច័ន្ទ ទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ វិញ តាមការស្នើសុំរបស់ភាគីដែលពាក់ព័ន្ធ និងដោយអនុលោមតាមវិធាន ៣៩ (៤) នៃវិធានផ្ទៃក្នុង ។

**សូមបញ្ជាក់ថា** អង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីទាំងអស់នៅពេលក្រោយអំពីថ្ងៃសវនាការសម្រាប់សប្ដាហ៍ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ ២០០៩។

**សូមបញ្ជាក់បន្ថែមថា** ថ្ងៃសវនាការបន្តបន្ទាប់ទៀត នឹងត្រូវកំណត់នៅពេលក្រោយ។

**សូមជូនដំណឹងបន្ថែមដល់ភាគីទាំងអស់ថា** ដីកាសម្រេចស្ដីពីការកំណត់លំដាប់លំដោយនៃការកោះហៅសាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី នឹងត្រូវចេញរៀងរាល់សប្ដាហ៍ទីបីនៃខែ សម្រាប់ខែបន្ទាប់។

**សម្រេចបន្ថែមថា** សេចក្ដីសម្រេចនេះ ត្រូវជូនដំណឹងទៅភាគីទាំងអស់ និងទៅការិយាល័យរដ្ឋបាល ហើយនឹងត្រូវចុះផ្សាយនៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក.។

ភ្នំពេញ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIERE INSTANCE E C C C

និល ណុន